អង្គការសមាគមធាងត្នោត

Sahmakum Teang Tnaut Organization · a Cambodian Urban NGO

ការពិត និងតួរលេខ #៥២

# ស្លាកស្នាមនៃការអភិវឌ្ឍបឹងតាមោក

## "ពលរដ្ឋ២៦នាក់ ត្រូវបានចោទប្រកាន់ដោយសារការពារដីធ្លី និងលំនៅឋាន" ករណីសហគមន៍សំរោងត្បូង

*ខែធ្នូ ឆ្នាំ២០២៤*



# មាតិកា


១. សេចក្តីសង្ខេប . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១
២. គោលបំណងនៃការស្រាវជ្រាវ . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៣
៣. វិធីសាស្ត្រស្រាវជ្រាវ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤
៤. សាវតានៃសហគមន៍សំរោងត្បូង . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥
៥. បណ្តឹងទាំង ៧ ដែលបានដាក់បន្ទុកលើសហគមន៍ . . . . . . . . . . . . . . . . . . . ៧
៦. ករណីលម្អិតទាំង ២៦នាក់ ដែលទទួលបណ្តឹង . . . . . . . . . . . . . . . . . . . . . ១១
៧. សំណង . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៥
៨. បច្ចុប្បន្នភាពនៃការការកាត់ផ្ទៃបឹង . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៧
៩.ការវិភាគផ្នែកច្បាប់ចំពោះលក្ខខណ្ឌនៃការកាន់កាប់ដីរបស់សហគមន៍ . . . . . . . . . . . . . . ១៨
១០. អនុសាសន៍ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ២២

# ១. សេចក្ដីសង្ខេប



*រូបភាពទី១៖ លំនៅឋានក្នុងសហគមន៍សំរោងត្បូងនៅទីតាំងថ្មី*

ចាប់តាំងពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៤ ប្រជាសហគមន៍សំរោងត្បូងចំនួន ២៦ រូប បានទទួលរងបណ្ដឹងចំនួន ៧ បណ្ដឹង តាមផ្លូវតុលាការ ដោយសារការការពារដីធ្លី និងផ្ទះសម្បែងដែលពួកគេធ្លាប់បានកាន់កាប់។ បណ្ដឹងទាំងនោះមាន ៥បណ្ដឹងកំពុងដំណើរការនីតិវិធីនៅតុលាការដំបូង មាន ១ បណ្ដឹង ត្រូវបានតម្កល់ទុកឥតចាត់ការ និង ១ បណ្ដឹងកំពុងប្ដឹងសាទុក្ខទៅតុលាការកំពូល ។ សំណុំរឿងភាគច្រើន គឺបានប្ដឹង ប្រជាពលរដ្ឋពីបទប្រឆាំងអ្នករាជការសាធារណៈនៅពេលអាជ្ញាធរចុះមករុះរើលំនៅឋានប្រជាពលរដ្ឋក្រោមហេតុផលថាប្រជាពលរដ្ឋរស់នៅលើដីបឹង។ តាមស្ថានភាពច្បាប់ និងការកាន់កាប់ដីរបស់ប្រជាពលរដ្ឋដែលមិនស្ថិតក្នុងដីបឹង ប្រជាពលរដ្ឋសហគមន៍សំរោងត្បូង មិនគួរត្រូវបានចាត់ទុកថាជាអ្នករស់នៅខុសច្បាប់នោះទេ ហើយពួកគេគួរតែទទួលបាននូវលទ្ធកម្មកម្មសិទ្ធិស្របតាមច្បាប់។ ក្នុងន័យនេះ មានន័យថាមិនគួរមានការចោទប្រកាន់ថាប្រជាពលរដ្ឋរស់នៅលើដីសាធារណៈរបស់រដ្ឋនោះទេ ហើយបើគ្មានការចោទប្រកាន់ប្រជាពលរដ្ឋរស់នៅលើដីរដ្ឋនោះក៏មិនគួរមានការចុះមកហាមឃាត់ ឬរុះរើសំណង់ប្រជាពលរដ្ឋនោះដែរ។ ម្យ៉ាងវិញទៀត ប្រសិនបើមានការចុះមករុះរើ នោះក៏មិនគួរមានការប្ដឹងតាមផ្លូវតុលាការដែរ ដោយហេតុថាទំនាស់កើតឡើងដោយសារភាគីទាំងពីរមានភាពយល់ឃើញខុសគ្នាចំពោះលក្ខខណ្ឌនៃការកាន់កាប់។ ប្រសិនបើប្រជាពលរដ្ឋជាអ្នកកាន់កាប់ស្របច្បាប់ ពួកគាត់គួរតែមានសិទ្ធិពេញលេញក្នុងការទទួលបាននូវកម្មសិទ្ធិដីធ្លីនោះ ស្របតាមច្បាប់ភូមិបាល និងក្រមរដ្ឋប្បវេណី។

ការផ្តល់សំណងគឺបានដោះស្រាយតាមបែបគោលនយោបាយ វាហាក់បីដូចជាបានកំណត់ថាប្រជាពលរដ្ឋរស់នៅខុសច្បាប់ ខណៈដែលដីពួកគាត់អាចស្ថិតនៅលើដីឯកជន។ ការដោះស្រាយតាមបែបគោលនយោបាយធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនបានបាត់បង់ផលប្រយោជន៍ និងសិទ្ធិក្នុងការកាន់កាប់ដីធ្លីរបស់ខ្លួន។ សំណងប្រជាពលរដ្ឋបានទទួលទាប បំផុតមួយម្ចាស់ខ្ទង់ផ្ទះទទួលបានផ្ទះផ្ទាល់ដី ទំហំ៤,៥ X ១២ ម៉ែត្រ លើដី ៤,៥ x ១៨ ម៉ែត្រ និងថវិកា បន្ថែមចំនួន ១ម៉ឺនដុល្លារសហរដ្ឋអាមេរិក និង ខ្ពស់បំផុតទទួលបានផ្ទះផ្ទាល់ដី ចំនួនបី លើដី ទំហំ ៤,៥ x ១៨ ម៉ែត្រ និងថវិកាបន្ថែម ៤ម៉ឺន ដុល្លារសហរដ្ឋអាមេរិក ឬបើគិតជាសាច់ប្រាក់ចន្លោះប្រហែលពី ជាង ៣ ទៅ ជាង១០ម៉ឺនដុល្លារសហរដ្ឋអាមេរិក។ ចំនួននេះបានទទួលច្រើនគួរសមបើប្រៀបនឹងទីតាំងផ្សេងៗដែលមានលក្ខខណ្ឌប្រហាក់ប្រហែល។ នេះជាការសាទរមួយ ក៏ប៉ុន្តែ បើផ្អែកលក្ខខណ្ឌកាន់កាប់ និងស្ថានភាពដីរបស់ពួកគាត់ដែលកំពុងកាន់កាប់ គឺមាន លក្ខខណ្ឌមិនប៉ះពាល់ដល់ដីបឹង និងមិនប៉ះពាល់ដល់ការពង្រីកផ្លូវ ពោលគឺមានសក្តានុពលក្នុងការអភិវឌ្ឍនៅនឹងកន្លែងបាន ដូច្នេះសំណងនេះ គឺមានលក្ខខណ្ឌមិនទាន់ល្អប្រសើរ និងមិនទាន់យុត្តិធម៌នៅឡើយ។ បន្ថែមពីនោះ គ្រួសារមួយចំនួនបានទទួលសំណងក្រោមការបង្ខិតបង្ខំដាក់សម្ពាធឱ្យមានការទទួលយកសំណង។ ការដោះដូរនេះក៏បាន ធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ច ការរស់នៅ ផ្លូវចិត្តរបស់ពួកគាត់ផងដែរ។

អនុសាសន៍ចំនួន៧ ត្រូវបានដាក់ចេញទៅកាន់អាជ្ញាធរដែលពាក់ព័ន្ធរួមមាន៖ *ទី១* ការកំណត់ទីតាំងណាមួយជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋត្រូវមានការផ្សព្វផ្សាយ និងត្រូវទុកពេលឱ្យមានការប្តឹងតវ៉ាពីអ្នកពាក់ព័ន្ធ។ *ទី២* ការធ្វើអនុប្បយោគទីតាំងណាមួយ ត្រូវតែមានការចូលរួមពីប្រជាពលរដ្ឋ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ ជាពិសេសក្នុងដំណាក់កាលនៃនីតិវិធី។ *ទី៣* ក្នុងដំណើរការដោះស្រាយសំណងគួរបើកចំហសម្រាប់សាធារណជនគួរត្រូវបានធ្វើឡើងដើម្បីផ្សព្វផ្សាយ និងចោទជាសំណួរផ្សេងៗ ដើម្បីជំរុញការដោះស្រាយកាន់តែមានតម្លាភាព យុត្តិធម៌ និងអាចទទួលយកបានសម្រាប់អ្នករងផលប៉ះពាល់ផ្ទាល់ និងសាធារណៈជនទូទៅ។ *ទី៤* គួរមានយន្តការ ដែលប្រជាពលរដ្ឋតតាំងក្តីជាមួយអាជ្ញាធររដ្ឋដើម្បីសម្រេចពីភាពស្របច្បាប់ ឬមិនស្របច្បាប់របស់ខ្លួន តាមផ្លូវរដ្ឋប្បវេណី ចំពោះការកាន់កាប់របស់ខ្លួន ក្នុងនោះក៏គួរបើកសិទ្ធិឱ្យតតីយជនធ្វើជាដើមបណ្តឹងជំនួសប្រជាពលរដ្ឋផងដែរ។ *ទី៥* អាជ្ញាធរថ្នាក់ជាតិ នៅពេលបានទទួលសំណូមពររកអន្តរាគមន៍ដំណោះស្រាយពីប្រជាពលរដ្ឋមូលដ្ឋាន គួរមានយន្តការចុះអង្កេត និងវាយតម្លៃជាក់ស្តែងដោយផ្អែកលើគោលការណ៍ច្បាប់ និងសង្គម ដើម្បីឱ្យប្រជាពលរដ្ឋមានទំនុកចិត្ត។ *ទី៦* ត្រូវធានាថាការអភិវឌ្ឍត្រូវផ្តល់ផលប្រយោជន៍ជាអាទិភាពសម្រាប់ប្រជាពលរដ្ឋមូលដ្ឋាន។ បើមិនអាចអភិវឌ្ឍនៅកន្លែងបាន ការដោះដូរទីតាំងថ្មីត្រូវធានាថាជីវភាព និងស្ថានភាពរស់នៅរបស់ពួកគាត់មានភាពប្រសើរជាមុន ឬយ៉ាងហោចណាស់បានស្មើនឹងកន្លែងចាស់។ ចុងក្រោយ តុលាការគួរពិចារណាឱ្យបានស៊ីជម្រៅចំពោះការចោទប្រកាន់ថាប្រជាពលរដ្ឋប្រើប្រាស់ហិង្សា។

# ២. គោលបំណងស្រាវជ្រាវ



*រូបភាពទី២៖ ទីតាំងសហគមន៍ថ្មី*

អង្គការសមាគមធាងត្នោតសិក្សាស្រាវជ្រាវ និងចងក្រងឯកសារនេះឡើង ក្នុងគោលបំណង ប្រមូលនូវព័ត៌មានរបស់សហគមន៍សំរោងត្បូង ដែលជាសហគមន៍រងផលប៉ះពាល់ដោយផ្ទាល់ពី ការអភិវឌ្ឍបឹងតាមោក សម្រាប់ជាចំណេះដឹងដល់សាធារណជន និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីពិចារណា និងធ្វើឱ្យប្រសើរឡើងចំពោះកិច្ចការអភិវឌ្ឍនានា នៅពេលខាងមុខ។ អង្គការសមាគមធាងត្នោតក៏ចង់ឱ្យសាធារណជនបានយល់ឱ្យកាន់តែស៊ីជម្រៅចំពោះ ករណីបណ្តឹងមកលើសហគមន៍ដោយសារតែការការពារដីធ្លី និងផ្ទះសម្បែងរបស់ពួកគេ ដែលមកដល់បច្ចុប្បន្នមានសមាជិកសហគមន៍ចំនួន ២៦រូប ត្រូវបានប្តឹងទៅតុលាការ លើសំណុំរឿងចំនួន ៧ ដែលអាចនិយាយបានថាជាករណីច្រើនជាងគេនៅប្រទេសកម្ពុជា។

បន្ថែមពីនេះទៅទៀត បើទោះបីជាមានគ្រួសារជាច្រើនបានព្រមទទួលសំណងតែក៏នៅមាន គ្រួសារខ្លះដែលមិនទាន់ព្រមទទួលសំណង ដូច្នេះរបាយការណ៍អាចនឹងមានប្រយោជន៍សម្រាប់គ្រួសារដែលនៅសល់។ មួយវិញទៀត បើទោះបីជារឿងលំនៅឋានគាត់ស្ទើរតែបានបញ្ចប់ ក៏ប៉ុន្តែរឿងបណ្តឹងព្រហ្មទណ្ឌរបស់ពួកគាត់នៅតុលាការនៅតែបន្តនៅឡើយ។ ដូច្នេះរបាយការណ៍នេះអាចជាព័ត៌មានដ៏មានប្រយោជន៍សម្រាប់សហគមន៍ និងតុលាការក្នុងការសម្រេចសេចក្តី។ ជាចុងក្រោយ ករណីនេះអាចជាឧទាហរណ៍សម្រាប់ការពិចារណាសម្រាប់ទីតាំងផ្សេងទៀតនៅប្រទេសកម្ពុជា ដែលធ្វើឱ្យការសិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយនេះមានសារៈសំខាន់សម្រាប់សាធារណជន។

# ៣. វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវនេះ គឺផ្អែកលើការចុះអង្កេត និងប្រមូលព័ត៌មានដោយផ្ទាល់ និងជាប្រចាំរបស់អង្គការសមាគមជាងត្នោតចាប់តាំងពីឆ្នាំ២០១៩ និងបន្តមកដល់ខែវិច្ឆិកា ឆ្នាំ២០២៤។ អង្គការសមាគមជាងត្នោត តែងតែមានទំនាក់ទំនងល្អជាមួយសមាជិកសហគមន៍ ហើយក្រុមការងារតែងតែទទួលបាននូវបច្ចុប្បន្នភាពព័ត៌មានត្រូវបានផ្ទៀងផ្ទាត់ ចងក្រង និងរក្សាទុក។ ការប្រជុំពិភាក្សាជាមួយ សមាជិកសហគមន៍ ដែលទទួលរងបណ្ដឹង ក៏ត្រូវបានធ្វើឡើងនៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៤ ដើម្បីផ្ទៀងផ្ទាត់ទិន្នន័យឱ្យកាន់តែច្បាស់។ បន្ថែមពីនេះទៀត ដោយសារសំណាងត្រូវបានចរចារ និងដោះស្រាយ ដោយផ្ទាល់ជាបន្តបន្ទាប់ចាប់តាំងពីដើមឆ្នាំ២០២៣ រហូតមកដល់ខែតុលា ឆ្នាំ២០២៤នេះ ដូច្នេះក្រុមការងាររបស់អង្គការសមាគមជាងត្នោត ក៏បានចងក្រង និងប្រមូលទិន្នន័យនោះទុក ដោយទទួលបានពីការសម្ភាសផ្ទាល់ពីគ្រួសារដែលទទួលសំណាងផ្ទាល់។ ការប្រមូលឯកសារច្បាប់ដែលពាក់ព័ន្ធ ដីធ្លី ការចុះអង្កេត និងប្រមូលទិន្នន័យតាមខ្នងផ្ទះនៅក្នុងឆ្នាំ២០១៩-២០២៣ និងការធ្វើបច្ចុប្បន្នភាពក្នុងឆ្នាំ២០២៤នេះ ក៏បានយកមកធ្វើជាមូលដ្ឋានសំខាន់ដើម្បីវិភាគទៅលើទិដ្ឋភាពនៃការកាន់កាប់ដីធ្លីរបស់សហគមន៍ផងដែរ។

ក្នុងចំណោម៩៨ ខ្នងផ្ទះ ក្នុងការសិក្សានេះ មានតែ ៣២ ខ្នងផ្ទះប៉ុណ្ណោះដែលក្រុមការងារនៃ អង្គការសមាគមជាងត្នោត បានប្រមូលទិន្នន័យពាក់ព័ន្ធជាមួយសំណាងដោយសារមូលហេតុមួយចំនួនដូចជា គ្រួសារខ្លះមិនហ៊ានផ្ដល់បទសម្ភាសដោយមូលហេតុផ្សេងៗ គ្រួសារខ្លះទទួលយកថវិកា និងបានចាកចេញទៅកន្លែងផ្សេង គ្រួសារខ្លះមិនអាចទាក់ទងបាន និងគ្រួសារខ្លះមិនទាន់ទទួលសំណាងនៅឡើយ។ អង្គការសមាគមជាងត្នោតបានដាក់លិខិតទៅអាជ្ញាធរ ខណ្ឌព្រែកព្នៅដែរ ក៏ប៉ុន្តែខាងសាលាខណ្ឌ មិនបានអនុញ្ញាតឱ្យមានការសម្ភាសទេ ដោយតម្រូវឱ្យមានការអនុញ្ញាតជាមុនពីសាលារាជធានីភ្នំពេញ។

# ៤. សាវតានៃសហគមន៍សំរោងត្បូង



*រូបភាពទី៣៖ សហគមន៍សំរោងទីតាំងចាស់ (មិនទាន់បណ្តេញចេញ)*

សំរោងត្បូង ជាឈ្មោះសហគមន៍មួយដែលបច្ចុប្បន្នមានទីតាំងនៅភូមិសំរោង សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។ សហគមន៍នេះ ដើមឡើយស្ថិតក្នុងភូមិសំរោង ឃុំសំរោង ស្រុកពញាឮ ខេត្តកណ្ដាល តែក្នុងឆ្នាំ២០១២ ទីតាំងនេះបានកាត់ចូលខណ្ឌសែនសុខ រាជធានីភ្នំពេញ និងក្រោយមកទៀតបានដូរមកខណ្ឌព្រែកព្នៅ ក្នុងឆ្នាំ២០១៥ រហូតមកដល់បច្ចុប្បន្ន។ សហគមន៍ បានមកតាំងទីលំនៅដំបូងក្នុងឆ្នាំ១៩៩៦[1] ដែលមានចំនួន ១៧ខ្នងផ្ទះ និង ៣៥គ្រួសារ។ ប្រជាសហគមន៍បានឱ្យដឹងថាទីតាំងដែលសហគមន៍កំពុងតាំងទីលំនៅនេះ កាលពីដំបូងឡើយ គឺជាដីស្រែប្រាំងរបស់ពួកគេ ដែលបានអាស្រ័យផលតាំងពីឆ្នាំ១៩៩៦។ គិតត្រឹមឆ្នាំ២០១៩ ចំនួនខ្នងផ្ទះរបស់សហគមន៍កើនឡើងដល់ ៩៨ខ្នងផ្ទះ និង១០២ គ្រួសារ។

ក្នុងឆ្នាំ២០១៩ បន្ទាប់ពីមានការកាត់ឆ្វៀលបឹងតាមោក និងមានការអភិវឌ្ឍផ្សេងៗ សហគមន៍ត្រូវបានបង្ខំឱ្យទៅរស់នៅទីតាំងផ្សេង។ សហគមន៍បានរៀបចំសកម្មភាពស្វែងរកអន្តរាគមន៍ដើម្បីដោះស្រាយលើបញ្ហាប្រឈមរបស់ពួកគេជាច្រើនដងពីស្ថាប័នថ្នាក់ជាតិកំពូលៗ ដូចជារដ្ឋសភា ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តែហាក់មិនមានដំណោះស្រាយសមស្រប ដែលអាចឱ្យសហគមន៍ទទួលយកបានឡើយ។

បើយោងតាមអនុក្រឹត្យដែលកំណត់ផ្ទៃបឹងតាមោកជាទ្រព្យសម្បត្តិសាធារណៈរបស់

១. ព័ត៌មានបានមកពីសម្ភាសតំណាងសហគមន៍សំរោងត្បូងក្នុងឆ្នាំ ២០២៤




*រូបភាពទី៤៖ ផ្ទះដែលជាថ្មីរនឹងការដោះដូរក្នុងអំឡុងពេលសាងសង់(ខាងឆ្វេង) និងផ្ទះសាងសង់ហើយ(ខាងស្តាំ)*

រដ្ឋក្នុងឆ្នាំ២០១៦[២] បានបង្ហាញថាសហគមន៍សំរោងត្បូងមិនបានស្ថិតនៅក្នុងផ្ទៃបឹងតាមោកនោះទេ ប៉ុន្តែក្នុងឆ្នាំ២០២៣ អាជ្ញាធរបានចោទប្រកាន់[៣]សហគមន៍ថា កំពុងរស់នៅលើដីចំណីផ្លូវសាធារណៈរបស់រដ្ឋដែលត្រូវពង្រីកដើម្បីបញ្ចៀសចរាចរណ៍ពីមហាវិថីឈ្នះ-ឈ្នះ មកកាន់ផ្លូវលេខ១៥១។ ក្រោយមកក្នុងឆ្នាំ២០២៤ មានការចោទប្រកាន់ថ្មីមួយបន្ថែមទៀតថា ប្រជាសហគមន៍កំពុងរស់នៅលើដីរបស់បុគ្គលឯកជនដែលជាកម្មសិទ្ធិរបស់អ្នកដទៃ។ ការណ៍នេះ ធ្វើឱ្យប្រជាសហគមន៍សំរោងត្បូងរងការបណ្តេញចេញបន្ថែមទៀត។ ជារឿយៗ នៅពេលសហគមន៍សាងសង់សំណង់ថ្មី អាជ្ញាធរមូលដ្ឋានតែងតែចុះមករុះរើសំណង់របស់ពួកគេ។ ជាការឆ្លើយតប សហគមន៍បានរួមគ្នាតវ៉ាចំពោះសកម្មភាពរារាំងរបស់អាជ្ញាធរទាំងនោះ។ ជាលទ្ធផល អាជ្ញាធរមូលដ្ឋានបានប្តឹងពួកគេទៅតុលាការពីសកម្មភាពទាំងនោះ ដែលគិតមកដល់បច្ចុប្បន្ន មានប្រជាសហគមន៍ចំនួន ២៦នាក់ កំពុងតែរងបណ្តឹងតាមផ្លូវតុលាការ ក្រោមបទចោទ ប្រឆាំងអ្នករាជការសាធារណៈ បង្កហិង្សា និងញុះញង់ជាដើម។ អ្នកផ្តល់បទសម្ភាសបានលើកឡើងថា *"ដោយសារជីវភាព គ្រួសារមួយចំនួនបានបង្ខំចិត្តយល់ព្រមទទួលយកសំណងជាបន្តបន្ទាប់"*។

---

២. អនុក្រឹត្យស្តីពី ការកំណត់ផ្ទៃបឹងតាមោក ទំហំ ៣ ២៣៩.៧ ស្ថិតក្នុងរាជធានីភ្នំពេញជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ, លេខ ២០ អនក្រ.បក, ០៣ ខែកុម្ភៈ ឆ្នាំ២០០៦។

៣. រដ្ឋបាលខណ្ឌព្រែកព្នៅ លិខិតលេខ០៥៧ស្តីពីការជម្រាបមកលោកឡុង គឹមយន និងអ្នកស្រី គង់ តឿ ម្ចាស់សំណង់រោងឈើ របាំងដែក ប្រក់ស័ង្កសី ទំហំ៣,៥ម៉ែត្រ គុណ៦ម៉ែត្រ ដែលកំពុងសាងសងដោយគ្មានច្បាប់អនុញ្ញាត និងសាងសងលើដីចំណីផ្លូវលេខ១៥១ ស្ថិតនៅភូមិសំរោងត្បូង សង្កាត់សំរោងខណ្ឌព្រែកព្នៅរាជធានីភ្នំពេញ។

# ៥. បណ្ដឹងទាំង៧ ដែលបានដាក់បន្ទុក លើសហគមន៍

សហគមន៍សំរោងត្បូងបានរងបណ្ដឹងតុលាការជាបន្តបន្ទាប់ ដោយគិតចាប់ពីឆ្នាំ២០២១ រហូតមកដល់ឆ្នាំ២០២៤។ បច្ចុប្បន្នសហគមន៍រងបណ្ដឹងចំនួន ៧បណ្ដឹង ដែលក្នុងចំណោមបណ្ដឹងទាំងនោះមាន ៥ បណ្ដឹង កំពុងដំណើរការនៅសាលាដំបូងរាជធានីភ្នំពេញ មួយបណ្ដឹងត្រូវបានសហគមន៍ប្ដឹងសាទុក្ខទៅតុលាការកំពូល និងមួយបណ្ដឹងទៀតបានតម្កល់ទុកឥតចាត់ការ។

***បណ្ដឹងលើកទី១*** កើតឡើងតាមរយៈសំណុំរឿងព្រហ្មទណ្ឌលេខ ២៩៥៧ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១។ ប្រជាពលរដ្ឋ ៥រូប ក្នុងសហគមន៍ ត្រូវបានចោទប្រកាន់ពីបទ *"ប្រឆាំងនឹង អ្នករាជការសាធារណៈមានស្ថានទម្ងន់ទោស"* នៅផ្លូវលេខ១៥១ ភូមិសំរោងត្បូង សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១។ តុលាការបានសម្រេចទោសចំពោះប្រជាពលរដ្ឋទាំង ៥រូប ដោយដាក់ពន្ធនាគារចំនួន ៨ខែ និងពិន័យជាប្រាក់ក្នុងម្នាក់ៗ ១លានរៀល។ នីតិវិធីសំណុំរឿងបានបន្តរហូតដល់ក្នុងឆ្នាំ២០២៤ នៅចំពោះមុខសាលាឧទ្ធរណ៍ សាលាឧទ្ធរណ៍បានតម្កល់សាលក្រមសាលាដំបូងទុកជាបានការ។ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤ ប្រជាសហគមន៍សំរោងត្បូងបានដាក់ពាក្យប្ដឹងសាទុក្ខទៅនឹងសាលដីការបស់សាលាឧទ្ធរណ៍ទៅតុលាការកំពូល។ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ ប្រជាពលរដ្ឋបានដាក់សារណាការពារទៅតុលាកំពូល។ ប្រជាពលរដ្ឋទាំង៥ រូបនោះមានឈ្មោះ អ៊ំ គឿន ភេទស្រី អាយុ៥៣ឆ្នាំ ឈ្មោះ ខុន ដោរី ភេទស្រី អាយុ២៨ឆ្នាំ ឈ្មោះ ស៊ួន សៅ ភេទប្រុស អាយុ៤៦ឆ្នាំ ឈ្មោះ ខុន ដោរ៉ា ភេទស្រី អាយុ២៦ឆ្នាំ និងឈ្មោះ ស៊ា សំបាត់ ភេទប្រុស អាយុ៣៥ឆ្នាំ។

***បណ្ដឹងលើកទី២*** កើតឡើងតាមរយៈសំណុំរឿងព្រហ្មទណ្ឌលេខ ២៧០៧ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។ ប្រជាពលរដ្ឋចំនួន ៧រូប ត្រូវបានសាលាដំបូងរាជធានីភ្នំពេញចេញដីការកោះហៅចូលមកឆ្លើយបំភ្លឺនៅថ្ងៃទី៤ ខែមករា ឆ្នាំ២០២៤ ពីដំណើររឿង *"រារាំង ញុះញង់ បង្កើតសកម្មភាពអនាធិបតេយ្យតាមដងផ្លូវសាធារណៈ"* ដែលបានកើតឡើងនៅផ្លូវលេខ១៥១ ភូមិសំរោងត្បូង សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ និងថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២ យោងតាមពាក្យបណ្ដឹងរបស់លោក មាស សំបូរ។ បច្ចុប្បន្នសំណុំរឿងនេះកំពុងបន្តស្ថិតនៅសាលាដំបូងរាជធានីភ្នំពេញ។ ប្រជាពលរដ្ឋដែលត្រូវបានតុលាការកោះហៅមកឆ្លើយបំភ្លឺទាំង ៧រូប មានឈ្មោះ តាន់ ខ្ទី ភេទស្រី ឈ្មោះ ប្រាក់ សុភា ភេទស្រី ឈ្មោះ គង់ គឿ ភេទស្រី ឈ្មោះ ផន សុខុម ភេទស្រី ឈ្មោះ ផន សំ ភេទស្រី ឈ្មោះ ខេន សាអយ ភេទស្រី និងឈ្មោះ អំ យ៉េត ភេទស្រី។

***បណ្ដឹងលើកទី៣*** កើតឡើងតាមរយៈសំណុំរឿងព្រហ្មទណ្ឌ លេខ ៤៩៦១ ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។ ប្រជាពលរដ្ឋចំនួន ៩ រូប ត្រូវបានចោទប្រកាន់ពីបទ *"ហិង្សាដោយមានស្ថានទម្ងន់ទោស និងស្ថានទម្ងន់ទោសនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈ"* ដែលប្រព្រឹត្តនៅផ្លូវ១៥១ ភូមិសំរោង

ត្បូង សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣។ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣ សាលាដំបូងរាជធានីភ្នំពេញបានចេញលិខិតបិទបញ្ចប់ការស៊ើបសួរ។ សំណុំរឿងនេះ សាលាដំបូងរាជធានីភ្នំពេញបានសម្រេចផ្តន្ទាទោសប្រជាពលរដ្ឋទាំង៩នាក់ ដាក់ពន្ធធនាគារ ២ឆ្នាំ តែត្រូវព្យួរទោស។ ប្រជាពលរដ្ឋមិនបានប្តឹងទាស់ចំពោះការសម្រេចនេះទេ។ ប្រជាពលរដ្ឋទាំង ៩រូប មានឈ្មោះ សាយ សារិទ្ធិ ភេទប្រុស អាយុ៣៧ឆ្នាំ ឈ្មោះ សឿន ស្រីសុទ្ធ ភេទស្រី អាយុ៣២ឆ្នាំ ឈ្មោះ ប្រាក់ សុភា ភេទស្រី អាយុ៤៣ឆ្នាំ ឈ្មោះ គង់ គឿ ភេទស្រី អាយុ៦១ឆ្នាំ ឈ្មោះ តាន់ ខ្ចី អាយុ៤៥ឆ្នាំ ឈ្មោះ ផន សុខុម ភេទស្រី អាយុ៤៨ឆ្នាំ ឈ្មោះ យន គឹមឃឿន ភេទស្រី អាយុ៣០ឆ្នាំ ឈ្មោះ សឿន ចំរើន ភេទប្រុស អាយុប្រហែល៤០ឆ្នាំ និងឈ្មោះ ហេង នាង ភេទស្រី អាយុប្រហែល៥០ឆ្នាំ។

***បណ្តឹងលើកទី៤*** កើតឡើងតាមរយៈសំណុំរឿងព្រហ្មទណ្ឌលេខ ២៦៧៤ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ។ អ្នកស្រី អ៊ំ គឿន ប្រជាសហគមន៍សំរោងត្បូង បានទទួលពាក្យបណ្តឹងរបស់ លោក ងួន ម៉ុង ប្តឹងអ្នកស្រីក្រោមបទចោទ *"រំលោភកាន់កាប់អចលនវត្ថុដោយចេតនា និងប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត"*។ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចេញដីការកោះហៅអ្នកស្រីឱ្យចូលឆ្លើយបំភ្លឺចំនួន ២លើក លើកទី១ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ និងលើកទី២ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣។ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ មេធាវីរបស់អ្នកស្រី អ៊ំ គឿន បានឆ្លើយបំភ្លឺនៅតុលាការ ជាលទ្ធផលសាលាដំបូងរាជធានីភ្នំពេញបានតម្កល់ទុកឥតចាត់ការចំពោះសំណុំរឿងនេះ។

***បណ្តឹងលើកទី៥*** កើតឡើងតាមរយៈសំណុំរឿងព្រហ្មទណ្ឌលេខ ២៧២៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ។ ប្រជាសហគមន៍ចំនួន ៣រូប ត្រូវបានចោទប្រកាន់ពីបទ *"ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងប្រឆាំងនឹងអ្នករាជការសាធារណៈមានស្ថានទម្ងន់ទោស (យកឈើ ចាក់បំបុកក្រុមការងាររដ្ឋបាលខណ្ឌចុះរៀបចំសណ្តាប់ធ្នាប់)"* ដែលប្រព្រឹត្តនៅផ្លូវ១៥១ ភូមិសំរោងត្បូង សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៣។ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣ សាលាដំបូងរាជធានីភ្នំពេញបានចេញលិខិតបិទបញ្ចប់ការស៊ើបសួរ។ កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤ សាលាដំបូងរាជធានីភ្នំពេញបានបើកសវនាការកំបាំងមុខ និងថ្ងៃទី៣០ ខែកក្កដា ២០២៤ តុលាការបានសម្រេចចេញសាលក្រមកំបាំងមុខ(តាមការបញ្ជាក់របស់មេធាវី)។ ប្រជាពលរដ្ឋដែលត្រូវបានចោទប្រកាន់មានឈ្មោះ សឿន ស្រីសុទ្ធ ភេទស្រី អាយុ៣២ឆ្នាំ ឈ្មោះ ប្រាក់ សុភា ភេទស្រី អាយុ៤៣ឆ្នាំ និងឈ្មោះ ស៊ា ដារី ភេទស្រី អាយុ៤១ឆ្នាំ។

***បណ្តឹងលើកទី៦*** កើតឡើងតាមរយៈសំណុំរឿងព្រហ្មទណ្ឌលេខ ៧៤៣៧ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ។ ប្រជាពលរដ្ឋចំនួន ៧រូប ត្រូវបានសាលាដំបូងរាជធានីភ្នំពេញចេញដីការកោះហៅចូលមកឆ្លើយបំភ្លឺនៅថ្ងៃទី៤ ខែមករា ឆ្នាំ២០២៤ ពីដំណើររឿង *"ហិង្សាដោយចេតនា ធ្វើឱ្យខូចខាតដោយចេតនា និងប្រឆាំងនឹងអ្នករាជការសាធារណៈ"* តាមបណ្តឹងរបស់ឈ្មោះ សុខ បាន។ រហូតបច្ចុប្បន្នសំណុំរឿងនេះកំពុងបន្តស្ថិតនៅសាលាដំបូងរាជធានីភ្នំពេញ។ ប្រជាពលរដ្ឋដែលត្រូវបានតុលាការកោះហៅមកឆ្លើយបំភ្លឺមានឈ្មោះ

យន គឹមយ៉ុន ភេទប្រុស អាយុ ៣៤ឆ្នាំ ឈ្មោះ គឹម យន ភេទប្រុស អាយុ ៦១ឆ្នាំ ឈ្មោះ យន សម្បត្តិ ភេទស្រី អាយុ ១៩ឆ្នាំ ឈ្មោះ គង់ តឿ ភេទស្រី អាយុ ៦១ឆ្នាំ ឈ្មោះ យន គឹមយឿន ភេទស្រី អាយុ ៣០ឆ្នាំ និងឈ្មោះ អ៊ំ កឿន ភេទស្រី អាយុ ៥៣ឆ្នាំ និងតាន់ នី។ កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៤ សាលាដំបូងរាជធានីភ្នំពេញបានផ្តន្ទាទោសសមាជិកសហគមន៍សំពោងត្បូងបីរូបរួមមានអ្នកស្រី គង់ តឿ អ្នកស្រី យន គឹមយឿន និងកញ្ញា យន សម្បត្តិ ពីបទ *"ស្ពានទម្ងន់ទោសនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈ"* មាត្រា ៥០៤ នៃក្រមព្រហ្មទណ្ឌ។ ពួកគេត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ខែ និងពិន័យជាប្រាក់ ១លានរៀល ក្នុងម្នាក់ ប៉ុន្តែទោសទាំងនេះត្រូវបានព្យួរទាំងមូល។

**បណ្តឹងលើកទី៧** កើតឡើងតាមរយៈសំណុំរឿងព្រហ្មទណ្ឌលេខ ១៩៦៥ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤ របស់សាលាដំបូងរាជធានីភ្នំពេញ។ ប្រជាពលរដ្ឋចំនួន ១០រូប ត្រូវបានចោទប្រកាន់ពីបទ *"បទហិង្សាដោយចេតនា (ចាក់សាំងដុតស្បៃមុងបណ្តាលឱ្យឆាបឆេះរងរបួស)"*។ នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៤ ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញបានចេញដីកាបង្គាប់ឱ្យចូលខ្លួនចំពោះប្រជាសហគមន៍ ៩រូបទៅឆ្លើយបំភ្លឺ។ រហូតបច្ចុប្បន្នសំណុំរឿងនេះកំពុងបន្តស្ថិតនៅសាលាដំបូងរាជធានីភ្នំពេញ។ ប្រជាពលរដ្ឋដែលត្រូវបានចោទប្រកាន់មានឈ្មោះ អ៊ុត អាត ភេទប្រុស អាយុ ៤៦ឆ្នាំ ឈ្មោះ ស៊ា សំបាត់ ភេទប្រុស អាយុ ៣៩ឆ្នាំ ឈ្មោះ យន សម្បត្តិ ភេទស្រី អាយុ ១៩ឆ្នាំ ឈ្មោះ គង់ តឿ ភេទស្រី អាយុ ៦១ឆ្នាំ ឈ្មោះ ស៊ា ដាវី ភេទស្រី អាយុ ៤១ឆ្នាំ ឈ្មោះ ទឹក អ៊ុក ភេទស្រី អាយុ ៤៦ឆ្នាំ ឈ្មោះ យ៉ុង ស្រីណុច ភេទស្រី អាយុ ២៤ឆ្នាំ ឈ្មោះ អ៊ំ កឿន ភេទស្រី អាយុ ៥៣ឆ្នាំ និងឈ្មោះ អំ យុក ភេទស្រី អាយុ ៦០ឆ្នាំ និងចាន់ ទី ភេទស្រី អាយុ ៣៥ ឆ្នាំ។



*រូបភាពទី៥៖ រូបថតស្ត្រី២នាក់នៅសហគមន៍សំពោងត្បូងដែលបានចងនៅខាងមុខផ្ទះ*



រូបភាពទី៦៖ ទិដ្ឋភាពខាងក្រោយសហគមន៍សំរោងត្បូង

# ៦. ករណីលម្អិតទាំង ២៦នាក់ ដែលទទួលបណ្តឹង

| ល.រ | ឈ្មោះអ្នករងការចោទប្រកាន់ | ភេទ | ឈ្មោះបទចោទ | ថ្ងៃចេញដីការ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | អ៊ំ ភឿន | ស្រី | បទប្រឆាំងនឹងអ្នករាជការសាធារណៈមានស្ថានទម្ងន់ទោស | ដីកាបង្គាប់ឱ្យចូលខ្លួនចុះថ្ងៃទី០៩ខែកញ្ញា ឆ្នាំ២០២១ | សាលាដំបូង និងឧទ្ធរណ៍បានសម្រេចដាក់ពន្ធនាគារចំនួន ៨ខែ និងពិន័យជាប្រាក់ ១លានរៀល។ សហគមន៍កំពុងប្តឹងសាទុក្ខទៅតុលាការកំពូល។ |
| | | | បទរំលោភកាន់កាប់អចលនវត្ថុដោយចេតនា និងប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត | ដីការកោះចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ | តុលាការទម្លាក់បទចោទ |
| | | | បទហិង្សាដោយចេតនាធ្វើឱ្យខូចខាតដោយចេតនា និងប្រឆាំងនឹងអ្នករាជការសាធារណៈ | ដីការកោះចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២៤ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| | | | បទហិង្សាដោយចេតនា (ចាក់សាំងដុតស្បៃមុងបណ្តាលឱ្យធាបឆេះរងរបួស) | ដីកាបង្គាប់ឱ្យចូលខ្លួន ចុះថ្ងៃទី០៩ កក្កដា ឆ្នាំ២០២៤ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| ២ | ខុន ដេរី | ស្រី | បទប្រឆាំងនឹងអ្នករាជការសាធារណៈមានស្ថានទម្ងន់ទោស | ដីកាបង្គាប់ឱ្យចូលខ្លួនចុះថ្ងៃទី០៩ខែកញ្ញា ឆ្នាំ២០២១ | សាលាដំបូង និងឧទ្ធរណ៍បានសម្រេចដាក់ពន្ធនាគារចំនួន ៨ខែ និងពិន័យជាប្រាក់ ១លានរៀល។ សហគមន៍កំពុងប្តឹងសាទុក្ខទៅតុលាការកំពូល។ |
| ៣ | ស៊ួន សៅ | ប្រុស | បទប្រឆាំងនឹងអ្នករាជការសាធារណៈមានស្ថានទម្ងន់ទោស | ដីកាបង្គាប់ឱ្យចូលខ្លួនចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ | សាលាដំបូង និងឧទ្ធរណ៍បានសម្រេចដាក់ពន្ធនាគារចំនួន ៨ខែ និងពិន័យជាប្រាក់ ១លានរៀល។ សហគមន៍កំពុងប្តឹងសាទុក្ខទៅតុលាការកំពូល។ |
| ៤ | ខុន ដេរ៉ា | ស្រី | បទប្រឆាំងនឹងអ្នករាជការសាធារណៈមានស្ថានទម្ងន់ទោស | ដីកាបង្គាប់ឱ្យចូលខ្លួនចុះថ្ងៃទី០៩ខែកញ្ញា ឆ្នាំ២០២១ | សាលាដំបូង និងឧទ្ធរណ៍បានសម្រេចដាក់ពន្ធនាគារចំនួន ៨ខែ និងពិន័យជាប្រាក់ ១លានរៀល។ សហគមន៍កំពុងប្តឹងសាទុក្ខទៅតុលាការកំពូល។ |

| | | | | | |
|---|---|---|---|---|---|
| ៥ | ស៊ា សំបាត់ | ប្រុស | បទប្រឆាំងនឹងអ្នករាជការសាធារណៈមានស្ថានទម្ងន់ទោស | ដីកាបង្គាប់ឱ្យចូលខ្លួនចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ | សាលាដំបូង និងឧទ្ធរណ៍បានសម្រេចដាក់ពន្ធនាគារចំនួន ៨ខែ និងពិន័យជាប្រាក់ ១លានរៀល។ សហគមន៍កំពុងប្តឹងសាទុក្ខទៅតុលាការកំពូល។ |
| | | | បទហិង្សាដោយចេតនា (ចាក់សាំងដុតស្បៃមុងបណ្តាលឱ្យឆាបឆេះរងរបួស) | ដីកាបង្គាប់ឱ្យចូលខ្លួនចុះថ្ងៃទី០៩ កក្កដា ឆ្នាំ២០២៤ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| ៦ | សាយ សារិទ្ធិ | ប្រុស | បទហិង្សាដោយមានស្ថានទម្ងន់ទោស និងស្ថានទម្ងន់ទោសនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈ | ដីការកោះចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៣ | សាលាដំបូងរាជធានីភ្នំពេញបានសម្រេចផ្តន្ទាទោស ដាក់ពន្ធធនាគារ ២ឆ្នាំ តែត្រូវព្យួរទោស។ |
| ៧ | សឿន ស្រីសុទ្ធ | ស្រី | បទហិង្សាដោយមានស្ថានទម្ងន់ទោស និងស្ថានទម្ងន់ទោសនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈ | ដីការកោះចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៣ | សាលាដំបូងរាជធានីភ្នំពេញបានសម្រេចផ្តន្ទាទោស ដាក់ពន្ធធនាគារ ២ឆ្នាំ តែត្រូវព្យួរទោស។ |
| | | | បទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងប្រឆាំងនឹងអ្នករាជការសាធារណៈមានស្ថានទម្ងន់ទោស (យកឈើចាក់បំបុកក្រុមការងាររដ្ឋបាលខណ្ឌចុះរៀបចំសណ្តាប់ធ្នាប់) | ដីកាបង្គាប់ឱ្យចូលខ្លួនចុះថ្ងៃទី២៩ខែកញ្ញា ឆ្នាំ២០២៣ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| ៨ | ប្រាក់ សុភា | ស្រី | បទហិង្សាដោយមានស្ថានទម្ងន់ទោស និងស្ថានទម្ងន់ទោសនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈ | ដីការកោះចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៣ | សាលាដំបូងរាជធានីភ្នំពេញបានសម្រេចផ្តន្ទាទោស ដាក់ពន្ធធនាគារ ២ឆ្នាំ តែត្រូវព្យួរទោស។ |
| | | | បទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងប្រឆាំងនឹងអ្នករាជការសាធារណៈមានស្ថានទម្ងន់ទោស (យកឈើចាក់បំបុកក្រុមការងាររដ្ឋបាលខណ្ឌចុះរៀបចំសណ្តាប់ធ្នាប់) | ដីកាបង្គាប់ឱ្យចូលខ្លួនចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| | | | បទរាំង ញុះញង់ បង្កើតសកម្មភាពអនាធិបតេយ្យតាមដងផ្លូវសាធារណៈ | ដីការកោះចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| ៩ | គង់ តឿ | ស្រី | បទហិង្សាដោយមានស្ថានទម្ងន់ទោស និងស្ថានទម្ងន់ទោសនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈ | ដីការកោះចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៣ | សាលាដំបូងរាជធានីភ្នំពេញបានសម្រេចផ្តន្ទាទោស ដាក់ពន្ធធនាគារ២ឆ្នាំ តែត្រូវព្យួរទោស។ |
| | | | បទរាំង ញុះញង់ បង្កើតសកម្មភាពអនាធិបតេយ្យតាមដងផ្លូវសាធារណៈ | ដីការកោះចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| | | | ហិង្សាដោយចេតនា ធ្វើឱ្យខូចខាតដោយចេតនា និងប្រឆាំងនឹងអ្នករាជការសាធារណៈ | ដីការកោះចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២៤ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| | | | បទហិង្សាដោយចេតនា (ចាក់សាំងដុតស្បៃមុងបណ្តាលឱ្យឆាបឆេះរងរបួស) | ដីកាបង្គាប់ឱ្យចូលខ្លួនចុះថ្ងៃទី០៩ កក្កដា ឆ្នាំ២០២៤ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |

| | | | | | |
|---|---|---|---|---|---|
| ១០ | តាន់ ខ្វី | ស្រី | បទរារាំង ញុះញង់ បង្កើតសកម្មភាពអនាធិបតេយ្យតាមដងផ្លូវសាធារណៈ | ជីការកោះចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| | | | បទហិង្សាដោយមានស្ថានទម្ងន់ទោស និងស្ថានទម្ងន់ទោសនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈ | ដីការកោះចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៣ | សាលាដំបូងរាជធានីភ្នំពេញបានសម្រេចផ្តន្ទាទោស ដាក់ពន្ធធនាគារ២ឆ្នាំ តែត្រូវព្យួរទោស។ |
| | | | ហិង្សាដោយចេតនា ធ្វើឱ្យខូចខាតដោយចេតនា និងប្រឆាំងនឹងអ្នករាជការសាធារណៈ | ដីការកោះចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៣ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| ១១ | ផន សុខុម | ស្រី | បទរារាំង ញុះញង់ បង្កើតសកម្មភាពអនាធិបតេយ្យតាមដងផ្លូវសាធារណៈ | ដីការកោះចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| | | | បទហិង្សាដោយមានស្ថានទម្ងន់ទោស និងស្ថានទម្ងន់ទោសនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈ | ដីការកោះចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៣ | សាលាដំបូងរាជធានីភ្នំពេញបានសម្រេចផ្តន្ទាទោស ដាក់ពន្ធធនាគារ២ឆ្នាំ តែត្រូវព្យួរទោស។ |
| ១២ | យន គឹមយឿន | ស្រី | បទហិង្សាដោយមានស្ថានទម្ងន់ទោស និងស្ថានទម្ងន់ទោសនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈ | ដីការកោះចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៣ | សាលាដំបូងរាជធានីភ្នំពេញបានសម្រេចផ្តន្ទាទោស ដាក់ពន្ធធនាគារ២ឆ្នាំ តែត្រូវព្យួរទោស។ |
| | | | ហិង្សាដោយចេតនា ធ្វើឱ្យខូចខាតដោយចេតនា និងប្រឆាំងនឹងអ្នករាជការសាធារណៈ | ដីការកោះចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៣ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| ១៣ | សឿន ចំរើន | ប្រុស | បទហិង្សាដោយមានស្ថានទម្ងន់ទោស និងស្ថានទម្ងន់ទោសនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈ | ដីការកោះចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៣ | សាលាដំបូងរាជធានីភ្នំពេញបានសម្រេចផ្តន្ទាទោស ដាក់ពន្ធធនាគារ២ឆ្នាំ តែត្រូវព្យួរទោស។ |
| ១៤ | ហេង នាង | ស្រី | បទហិង្សាដោយមានស្ថានទម្ងន់ទោស និងស្ថានទម្ងន់ទោសនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈ | ដីការកោះចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៣ | សាលាដំបូងរាជធានីភ្នំពេញបានសម្រេចផ្តន្ទាទោស ដាក់ពន្ធធនាគារ២ឆ្នាំ តែត្រូវព្យួរទោស។ |
| ១៥ | ស៊ា ដាវី | ស្រី | បទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងប្រឆាំងនឹងអ្នករាជការសាធារណៈមានស្ថានទម្ងន់ទោស (យកឈើចាក់បំបុកក្រុមការងាររដ្ឋបាលខណ្ឌចុះរៀបចំសណ្តាប់ធ្នាប់) | ដីការបង្គាប់ឱ្យចូលខ្លួនចុះថ្ងៃទី២៩ខែកញ្ញា ឆ្នាំ២០២៣ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| | | | បទហិង្សាដោយចេតនា (ចាក់សាំងដុតស្បែមុងបណ្តាលឱ្យឆាបឆេះរងរបួស) | ដីការបង្គាប់ឱ្យចូលខ្លួនចុះថ្ងៃទី០៩ កក្កដា ឆ្នាំ២០២៤ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| ១៦ | យន គឹមយ៉ុន | ប្រុស | ហិង្សាដោយចេតនា ធ្វើឱ្យខូចខាតដោយចេតនា និងប្រឆាំងនឹងអ្នករាជការសាធារណៈ | ដីការកោះចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២៤ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |

| | | | | | |
|---|---|---|---|---|---|
| ១៧ | គឹម យន | ប្រុស | ហិង្សាដោយចេតនា ធ្វើឱ្យខូចខាតដោយចេតនា និងប្រឆាំងនឹងអ្នករាជការសាធារណៈ | ដីការកោះចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២៤ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| ១៨ | យន សម្បត្តិ | ស្រី | ហិង្សាដោយចេតនា ធ្វើឱ្យខូចខាតដោយចេតនា និងប្រឆាំងនឹងអ្នករាជការសាធារណៈ | ដីការកោះចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២៤ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| | | | បទហិង្សាដោយចេតនា (ចាក់សាំងដុតស្បៃមុងបណ្តាលឱ្យឆាបឆេះរងរបួស) | ដីកាបង្គាប់ឱ្យចូលខ្លួនចុះថ្ងៃទី០៩ កក្កដា ឆ្នាំ២០២៤ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| ១៩ | ផន សំ | ស្រី | បទរារាំង ញុះញង់ បង្កើតសកម្មភាពអនាធិបតេយ្យតាមដងផ្លូវសាធារណៈ | ដីការកោះចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| ២០ | ខេន សាអយ | ស្រី | បទរារាំង ញុះញង់ បង្កើតសកម្មភាពអនាធិបតេយ្យតាមដងផ្លូវសាធារណៈ | ដីការកោះចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| ២១ | អំ យ៉េត | ស្រី | បទរារាំង ញុះញង់ បង្កើតសកម្មភាពអនាធិបតេយ្យតាមដងផ្លូវសាធារណៈ | ដីការកោះចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| ២២ | អំ យុក | ស្រី | បទហិង្សាដោយចេតនា (ចាក់សាំងដុតស្បៃមុងបណ្តាលឱ្យឆាបឆេះរងរបួស) | ដីកាបង្គាប់ឱ្យចូលខ្លួនចុះថ្ងៃទី០៩ កក្កដា ឆ្នាំ២០២៤ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| ២៣ | ទឹក អ៊ុក | ស្រី | បទហិង្សាដោយចេតនា (ចាក់សាំងដុតស្បៃមុងបណ្តាលឱ្យឆាបឆេះរងរបួស) | ដីកាបង្គាប់ឱ្យចូលខ្លួនចុះថ្ងៃទី០៩ កក្កដា ឆ្នាំ២០២៤ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| ២៤ | យ៉ុង ស្រីណុច | ស្រី | បទហិង្សាដោយចេតនា (ចាក់សាំងដុតស្បៃមុងបណ្តាលឱ្យឆាបឆេះរងរបួស) | ដីកាបង្គាប់ឱ្យចូលខ្លួនចុះថ្ងៃទី០៩ កក្កដា ឆ្នាំ២០២៤ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| ២៥ | អ៊ិត អាត | ប្រុស | បទហិង្សាដោយចេតនា (ចាក់សាំងដុតស្បៃមុងបណ្តាលឱ្យឆាបឆេះរងរបួស) | ដីកាបង្គាប់ឱ្យចូលខ្លួនចុះថ្ងៃទី០៩ កក្កដា ឆ្នាំ២០២៤ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |
| ២៦ | ចាន់ ទី | ស្រី | បទហិង្សាដោយចេតនា (ចាក់សាំងដុតស្បៃមុងបណ្តាលឱ្យឆាបឆេះរងរបួស) | ដីកាបង្គាប់ឱ្យចូលខ្លួនចុះថ្ងៃទី០៩ កក្កដា ឆ្នាំ២០២៤ | សំណុំរឿងកំពុងស្ថិតនៅសាលាដំបូង |

# ៧. សំណង

ក្នុងចំណោមសំណងនៃការដោះដូរ ក្នុងមួយម្ចាស់ខ្នងផ្ទះ ទទួលបានទាបបំផុត គឺផ្ទះផ្ទាល់ដីចំនួនមួយ ដែលមានទំហំ ៤,៥ x ១២ម៉ែត្រ លើដីទំហំ៤,៥ x ១៨ម៉ែត្រ និងទឹកប្រាក់បន្ថែមចំនួន ១ម៉ឺន ដុល្លារសហរដ្ឋអាមេរិក និងខ្ពស់បំផុតទទួលបាន ផ្ទះផ្ទាល់ដីចំនួន បីដែលមានទំហំ ៤,៥ x១២ម៉ែត្រ លើ ដីទំហំ៤,៥ x ១៨ម៉ែត្រ និងថវិកាចំនួន ៤ម៉ឺន ដុល្លារសហរដ្ឋអាមេរិក[៤]។ បើផ្អែកតាមព័ត៌មានពីប្រជាពលរដ្ឋ ដី មានតម្លៃប្រហាក់ប្រហែល ២ម៉ឺន៣ពាន់ដុល្លារ និងផ្ទះមានតម្លៃប្រហែល ៦ពាន់ដុល្លារ[៥] នេះ មានន័យថាបើគិតជាសាច់ប្រាក់ ពួកគាត់អាច ទទួលបានសំណងចន្លោះប្រហែលពីជាង ៣ម៉ឺន ទៅជាង១០ ម៉ឺនដុល្លារសហរដ្ឋអាមេរិក។ សំណងនេះ គឺមិនមានគោលការណ៍ជាក់លាក់នៅក្នុងការដោះស្រាយនោះទេ គឺដោះស្រាយតាមរយៈការចរចារ និងសម្របសម្រួលជាមួយគ្រួសារអ្នកដែលរងផលប៉ះពាល់នីមួយៗ។ យ៉ាងណា ក្នុងដំណើរការនិងទំហំសំណងដែលផ្តល់ជូន ប្រហែលជាអាចពាក់ព័ន្ធនឹងទំហំដីជាក់ស្តែង ចំនួនសមាជិកក្នុងគ្រួសារ និងតួនាទីរបស់ប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ផងដែរ។

បើទោះបីជាសំណងពួកគេទទួលបានច្រើនក្តី ក៏មានសមាជិកសហគមន៍ខ្លះមិនទាន់ពេញចិត្តជាមួយនឹងសំណងដែលពួកគេទទួលបានឡើយ យោងតាមព័ត៌មានដែលប្រមូលបាន ក្នុងចំណោម ៣២គ្រួសារដែលទទួលបានសំណងមានចំនួន ១០ គ្រួសារ ដែលពួកគាត់គិតថាសំណងទាំងនោះ មិនទាន់សមរម្យដែលអាចទទួលយកបានឡើយ ដោយហេតុថា ដីដែលគាត់ទទួលបានមិនស្មើនឹងដី ផ្ទះ នៅទីតាំងចាស់ សំណង់អាគារដែលផ្តល់ជូនមិនមានគុណភាព(ប្រេះ លូស្ទះ) ថវិកាដែលផ្តល់ជូនត្រូវចំណាយទៅស្ទើរទាំងតែអស់សម្រាប់ការកែលម្អលំនៅឋាន បាត់បង់មុខរបរ ចំណូលធ្លាក់ចុះ និងការចាកចេញទាំងភ័យខ្លាច។

តាមរយៈលទ្ធផលស្ទង់មតិ បង្ហាញឱ្យឃើញថាក្នុងចំណោម ៣២ គ្រួសារដែលបានផ្តល់បទសម្ភាស មានបីគ្រួសារ (៩%) មិនពេញចិត្តសោះ ខណៈ ពីរគ្រួសារទៀតពេញចិត្តខ្លាំង (៣%) ចំពោះសំណងដែលពួកគេទទួលបាន។ គួរឱ្យកត់សម្គាល់ផងដែរ ភាគច្រើននៃអ្នកផ្តល់បទសម្ភាស បានវាយតម្លៃកម្រិតពេញចិត្តមធ្យម ឬធម្មតា ដែលមានចំនួន ២១គ្រួសារ ឬស្មើរ៦៦%។ លទ្ធផលនៃការស្ទង់មតិនេះ អាចវិភាគបានថា ពួកគាត់មិនទាន់ពេញចិត្តទាំងស្រុងចំពោះសំណងដែលទទួលបាននៅឡើយទេ ដោយសារសារមូលហេតុផ្សេងៗដូចជា រយៈពេលនៃការកាន់កាប់ ឯកសារបញ្ជាក់ពីការកាន់កាប់ ទំហំដី ឬលំនៅឋាននៅទីតាំងចាស់ និងការមិនបានគិតគូរអំពីមុខរបរជាដើម។ ជាក់ស្តែងក្នុងចំណោម ៣២ គ្រួសារដែលបានផ្តល់បទសម្ភាស មាន ១៣ គ្រួសារ ដែលបានអះអាងថាគ្រួសាររបស់ពួកគេបានធ្លាក់ចុះប្រាក់ចំណូលពី ២០% ទៅ ៧៥% នៃប្រាក់ចំណូលដែលធ្លាប់រកបាន។

---

៤. ផ្ទះខ្លះនៅជាប់ផ្លូវធំទោះបីជាមានទំហំតូចជាងតែអាចមានតម្លៃប្រហាក់ប្រហែល ឬខ្ពស់ជាងនេះ អាស្រ័យលើការលក់ជាក់ស្តែង។
៥. លទ្ធផលផ្អែកតាមការពិភាក្សាក្រុម ដែលពួកគាត់ធ្លាប់បានដឹងជាបទពិសោធន៍នៃតម្លៃលក់ទិញ




*ក្រាហ្វិចទី១៖ ការវាយតម្លៃពេញចិត្ត ឬមិនពេញចិត្តចំពោះសំណាង*



*រូបភាពទី៧៖ រូបបុរសម្នាក់មានមុខរបរជាជាងជួសជុលម៉ូតូនៅទីតាំងចាស់ អាចប្រឈមនឹងការបាត់មុខរបរ*

# ៨. បច្ចុប្បន្នភាពនៃការកាត់ផ្ទៃបឹង

គិតត្រឹម ខែសីហា ឆ្នាំ២០២៤ ផ្ទៃបឹងតាមោកត្រូវបានកាត់ ឬធ្វើអនុប្បយោគប្រគល់ឱ្យឯកជន និងស្ថានប័នផ្សេងៗចំនួន ៨០ លើក ស្មើនឹង ២៤២៧,៣០៤៨ហិកតា ឬស្មើ ៧៤,៩២% នៃផ្ទៃបឹងទាំងមូល នេះមិនទាន់គិតផ្ទៃបឹងដែលបាត់បង់ ដែលកើតឡើងដោយការបម្រុងទុកសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់បម្រើឱ្យដីដែលបានកាត់ទាំងនោះឡើយ។ ការកែសម្រួលដ៏ច្រើនលើសលុបនេះ អាចនិយាយបានថាជាករណីនៃការធ្វើអនុប្បយោគដែលមានចំនួនច្រើនជាងគេបង្អស់នៅប្រទេសកម្ពុជា បើប្រៀបធៀបទៅហ្នឹងតំបន់ផ្សេងៗនៃដីសាធារណៈរបស់រដ្ឋនៃប្រទេសកម្ពុជាដែលបានទទួលការការពារ។ យោងតាមមាត្រា១៦ នៃច្បាប់ភូមិបាល ឆ្នាំ២០០១ បានកំណត់ថាការធ្វើអនុប្បយោគដីសាធារណៈរបស់រដ្ឋមកដីឯកជនរបស់រដ្ឋត្រូវកំណត់ដោយច្បាប់ បន្ទាប់ពីទ្រព្យសម្បត្តិទាំងនោះលែងបម្រើឱ្យផលប្រយោជន៍សាធារណៈ ក៏ប៉ុន្តែចាប់តាំងពីឆ្នាំនៃការបង្កើតច្បាប់ភូមិបាលឆ្នាំ២០០១ មកទល់បច្ចុប្បន្ន មិនទាន់មានដីសាធារណៈរបស់រដ្ឋណាមួយដែលបានធ្វើអនុប្បយោគដោយឆ្លងកាត់រដ្ឋសភាអនុម័តជាច្បាប់នោះឡើយ។




*ផែនទី១៖ ផែនទីដែលបញ្ជាក់ពីការកាត់បឹងតាមោកចន្លោះពីឆ្នាំ២០១២ ដល់ឆ្នាំ២០២៣*

# ៩. ការវិភាគផ្នែកច្បាប់ចំពោះលក្ខខណ្ឌនៃការកាន់កាប់ដីរបស់សហគមន៍

ដូចដែលបានរៀបរាប់ខ្លះៗ នៅផ្នែកសាវតារបស់សហគមន៍ *តើដីធ្លីដែលប្រជាសហគមន៍សំរោងត្បូងកំពុងរស់នៅបច្ចុប្បន្ននេះ ជាដីសាធារណៈរបស់រដ្ឋ ឬជារបស់បុគ្គលឯកជន? ឬជាដីឯកជនរបស់សហគមន៍? តើសហគមន៍សំរោងត្បូងអាចអភិវឌ្ឍនៅនឹងកន្លែងបានដែរ ឬទេ?*

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក៏ដូចជាច្បាប់ភូមិបាលឆ្នាំ២០០១ បានកំណត់ជាគោលការណ៍ច្បាប់ចំពោះបុគ្គល (រូបវន្តបុគ្គល ឬនីតិបុគ្គល) មានសញ្ជាតិខ្មែរ អាចទទួលបាននូវកម្មសិទ្ធិឯកជនលើដីធ្លី ឬអចលនវត្ថុ[៦]។ ការទទួលបាននូវកម្មសិទ្ធិឯកជនលើដីធ្លី ឬអចលនវត្ថុ លើដីឯកជនរបស់រដ្ឋមានជាអាទិ៍តាមរយៈអំណោយ ឬប្រទានកម្ម ការផ្តល់សម្បទានដីសង្គមកិច្ច ការដោះដូរ ឬការចូលទៅកាន់កាប់លើផ្នែកណាមួយនៃដីឯកជនរបស់រដ្ឋក្នុងបំណងយកមកធ្វើជាកម្មសិទ្ធិតាមរយៈភោគៈ[៧]។

តាមច្បាប់ភូមិបាល ឆ្នាំ២០០១ ដើម្បីក្លាយជាភោគៈស្របច្បាប់ និងមានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិជាស្ថាពរ ភោគីត្រូវបំពេញលក្ខខណ្ឌតម្រូវតាមច្បាប់ដូចជា បានអាស្រ័យផលនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី៥ឆ្នាំ យ៉ាងតិចគិតមកដល់ថ្ងៃទី៣០ ខែសីហាឆ្នាំ២០០១[៨]។ ម្យ៉ាងទៀត ដើម្បីក្លាយទៅជាកម្មសិទ្ធិករលើអចលនវត្ថុបានលុះត្រាតែភោគីនោះបានកាន់កាប់ដោយពិតប្រាកដ គ្មានហិង្សាដឹងឮជាសាធារណៈ គ្មានការអាក់ខាន និងដោយសុចរិត[៩]។ បន្ថែមពីនោះ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបើសិទ្ធិឱ្យមានការធ្វើលទ្ធកម្មកម្មសិទ្ធិទៅលើដីដែល ម្ចាស់បានទុកចោលទៅតាមពេលកំណត់។ សញ្ញាណនៃការកាន់កាប់នេះ បែកចែកជាពីរ គឺទី១ ជនកាន់កាប់អចលនវត្ថុអ្នកដទៃដោយមិនត្រឹមត្រូវ និងមានកំហុស និងទី២ ជនដែលកាន់កាប់អចលនវត្ថុដោយសុចរិត និងគ្មានកំហុស។ ទី១ ជនកាន់កាប់អចលនវត្ថុអ្នកដទៃដោយមិនត្រឹមត្រូវ និងមានកំហុសនឹងត្រូវទទួលបាននូវកម្មសិទ្ធិលើអចលនវត្ថុដែលខ្លួនបានកាន់កាប់ ក្នុងករណីជននោះ បានកាន់កាប់អចលនវត្ថុជាក់ស្តែង ដោយសន្តិវិធីដឹងឮជាសាធារណៈ និងដោយមានបំណងយកជាកម្មសិទ្ធិលើដីធ្លី ក្នុងអំឡុងពេល ២០ឆ្នាំ[១០]។ ទី២ ជនដែលកាន់កាប់អចលនវត្ថុដោយសុចរិត និងគ្មានកំហុសនឹងត្រូវទទួលបាននូវកម្មសិទ្ធិលើដីដែលខ្លួនបានកាន់កាប់ ក្នុងករណីជននោះបានកាន់កាប់ដីធ្លីជាក់ស្តែង ដោយសន្តិវិធី ដឹងឮជាសាធារណៈ ដោយមានឆន្ទៈយកជាកម្មសិទ្ធិលើដីធ្លីក្នុងអំឡុងពេល ១០ឆ្នាំ[១១]។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ និងច្បាប់ស្តីពីអស្សាមិករណ៍ឆ្នាំ២០១០ បានកំណត់ពីសិទ្ធិ

---

៦. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣, មាត្រា៤៤ និងច្បាប់ភូមិបាលឆ្នាំ ២០០១, មាត្រា១

៧. ច្បាប់ភូមិបាលឆ្នាំ ២០០១, មាត្រា១៧

៨. ច្បាប់ភូមិបាលឆ្នាំ ២០០១, មាត្រា៣០

៩. ច្បាប់ភូមិបាលឆ្នាំ ២០០១, មាត្រា៣៨

១០. ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា១៦២

១១. ច្បាប់ភូមិបាលឆ្នាំ ២០០១, មាត្រា៣៨ និងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១៦២។ ការបកស្រាយច្បាប់ចំពោះការអនុវត្តបទប្បញ្ញត្តិនៃមាត្រាទាំងនេះគឺអាចអនុវត្តចំពោះតែភោគី នៃលទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ(ជាភោគីដើម ឬសិទ្ធិវន្ត) ដែលកាន់កាប់ដីធ្លីដែលត្រូវបានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីរួចហើយតែប៉ុណ្ណោះ។ ការកាន់កាប់ស្របច្បាប់ទំនងជាមានន័យថា ការកាន់កាប់ដែលមានលិខិតយថាភូត ដែលបានទទួលស្គាល់ដោយមន្ត្រីមានសមត្ថកិច្ចក្នុងនីតិវិធីនៃការចុះបញ្ជីដីធ្លីផងដែរ។

ក្នុងការទទួលបានសំណងដោយសមរម្យ និងយុត្តិធម៌លើដីធ្លី ចំពោះទ្រព្យសម្បត្តិឯកជនដែលត្រូវបានរដ្ឋដកហូតដើម្បីយកទៅបម្រើប្រយោជន៍សាធារណៈ[១២]។

ច្បាប់ភូមិបាលបានធានានូវសិទ្ធិភោគៈដូចកម្មសិទ្ធិចំពោះភោគីស្របច្បាប់។ ក្នុងករណីមន្ត្រី ឬអាជ្ញាធរដែលបានប្រើអំណាចដោយរំលោភ ដើម្បីដកហូតអចលនវត្ថុពីអ្នកកាន់កាប់ដោយសន្តិភាពត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០លានរៀល ដល់ ២៥លានរៀល និង ត្រូវទទួលទោសរដ្ឋបាលថែមទៀត។ បើការដកហូតអចលនវត្ថុបានប្រព្រឹត្តទៅដោយអំពើហិង្សា ចារីត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ដល់ ២ឆ្នាំថែមទៀត។ អ្នកបញ្ជាដោយរំលោភត្រូវផ្តន្ទាទោសដូចគ្នានឹងអ្នកប្រព្រឹត្តផ្ទាល់ដែរ[១៣]។

ស្ថានភាពដីធ្លីរបស់សហគមន៍សំរោងត្បូង ទំនងជាដីឯកជនរបស់សហគមន៍ ព្រោះដីនោះមិនស្ថិតក្នុងផ្ទៃបឹងដែលកំណត់ផ្លូវការក្នុងឆ្នាំ២០១៦[១៤] មិនប៉ះពាល់ដល់ការពង្រីកផ្លូវ១៥១ ហើយពួកគាត់ខ្លះបានកាន់កាប់ដីនេះតាំងពីមុនឆ្នាំ២០០១ ពេលដែលដីនេះស្ថិតក្នុងស្ថានភាពជាដីស្រែប្រាំងម្លេះ។

ក្នុងឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ២០ អនក្រ.បក កំណត់ផ្ទៃបឹងតាមោក ឬបឹងកប់ស្រូវជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដោយមានទំហំសរុបចំនួន ៣២៣៩,៧ ហិកតា។[១៥] តាមរយៈអនុក្រឹត្យនេះ អាជ្ញាធរធ្លាប់បានអះអាងថាប្រជាពលរដ្ឋរស់នៅលើផ្ទៃបឹងតាមោកដែលជាដីសាធារណៈរបស់រដ្ឋ តែបើផ្ទៀងផ្ទាត់និយាមការកំណត់ផ្ទៃបឹង បានបង្ហាញថាទីតាំងដែលប្រជាសហគមន៍សំរោងត្បូងកំពុងរស់នៅមិនស្ថិតនៅលើផ្ទៃបឹងតាមោកនោះទេ។ ព្រំប្រទល់ផ្លូវការជាក់ស្តែងស្ថិតនៅចម្ងាយប្រមាណ ៤០ ទៅ ៧០ម៉ែត្រពីខាងក្រោយផ្ទះដែលពួកគេកំពុងតែរស់នៅ( សូមមើលផែនទីខាងក្រោម )[១៦] ។ នោះអាចបញ្ជាក់យ៉ាងច្បាស់ថា ការដែលលើកឡើងថាពលរដ្ឋរស់នៅក្នុងដីអនុក្រឹត្យគឺជារឿងខុស។ បន្ថែមពីនោះ ក្នុងពេលថ្មីៗ មានការលើកឡើងថា ប្រជាសហគមន៍គឺកំពុងរស់នៅលើផ្លូវ ១៥១ ដែលត្រូវការពង្រីក។ បើទោះបីជាដូចការរលើកឡើងឬផ្លូវនេះ ត្រូវពង្រីកឱ្យបាន ៥០ ម៉ែត្រពិតមែន ក៏សហគមន៍គឺពួកគាត់អាចរំកិល ទៅក្រោយបានដែលមានន័យថាបើទោះបីជាមានការពង្រីកផ្លូវ៥០ម៉ែត្រ ក៏សហគមន៍មានចន្លោះសុវត្ថិភាពប្រហែល៥០ម៉ែត្រផងដែរ( សូមមើលផែនទីខាងក្រោម )។

---

១២. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣, មាត្រា៤៤ និង ច្បាប់ស្តីពីអស្សាមិករណ៍ឆ្នាំ ២០០១, មាត្រា១
១៣. ច្បាប់ភូមិបាលឆ្នាំ ២០០១, មាត្រា២៦១
១៤. អង្គការសមាគមធាងត្នោត, ផែនទីអន្តរកម្មផ្ទៃបឹងតាមោក https://teangtnaut.org/km/map-layer ( ចូលមើលថ្ងៃទី ១៨ កក្កដា ២០២៤ )។
១៥. គជអប( NCDD) អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកំណត់ផ្ទៃបឹងតាមោក ( បឹងកប់ស្រូវ ) ទំហំ ៣.២៣៩.៧ ហិកតាស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ, តាមរយៈ៖ https://library.ncdd.gov.kh/detail/4083
១៦. អង្គការសមាគមធាងត្នោត, សហគមន៍សំរោងត្បូងបច្ចុប្បន្នភាពឆ្នាំ ២០២៤




*ផែនទីទី២៖ ផែនទីដែលបញ្ជាក់ថា សហគមន៍មិនស្ថិតក្នុងផ្ទៃបឹង និងមានឱកាសអភិវឌ្ឍនឹងកន្លែងបាន*

ប្រហែលសហគមន៍សំរោងត្បូងបានមករស់នៅចាប់តាំងពីឆ្នាំ១៩៩៦។[១៧] ការអាស្រ័យផលនៃភោគៈដោយសន្តិវិធី និងកាន់កាប់ដីធ្លីរបស់ប្រជាសហគមន៍ គឺកាន់កាប់ដោយមិនមានការចំណាយ និងតាមរយៈការទិញលក់ដោយម្ចាស់ដីធ្លីដំបូងបានកាន់កាប់មុនថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១។ ក្នុងនោះ ប្រជាសហគមន៍មួយចំនួនធំក៏មាននូវពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីមានបញ្ជាក់ពីភូមិ និងសង្កាត់ លិខិតជានាអះអាងលើដីធ្លីមានបញ្ជាក់ពីភូមិ និងសង្កាត់ កំណត់ហេតុស្តីពីការចុះពិនិត្យដីធ្លីមានបញ្ជាក់ពីភូមិ និងសង្កាត់ លិខិតបញ្ជាក់ប្រវត្តិដីមានបញ្ជាក់ពីភូមិ និងសង្កាត់ និងលិខិតបញ្ជាក់ទីលំនៅមានបញ្ជាក់ពីភូមិ និងសង្កាត់ផងដែរ។[១៨] នេះបង្ហាញកាន់តែច្បាស់ពីការទទួលស្គាល់របស់អាជ្ញាធរមូលដ្ឋាន ចំពោះការរស់នៅស្របច្បាប់របស់ប្រជាសហគមន៍សំរោងត្បូង។ អ្នករស់

នៅក្នុងសហគមន៍សំរោងត្បូងកន្លងមកបានអះអាងជាសាធារណៈថា ខ្លួនជាម្ចាស់នៃដីធ្លី និងផ្ទះសម្បែងចំពោះអាជ្ញាធរ និងតតិយជនផ្សេងទៀត តាំងពីពេលដែលមករស់នៅ ទីតាំងនេះដំបូង និងតែងតែមើលការថែទាំដីធ្លីផ្ទះសម្បែងរបស់ខ្លួនជានិច្ចមិនដែលអាក់ខានឡើយ។ ការហ៊ានអះអាងថាជាម្ចាស់ដីធ្លីចំពោះ

១៧. ច្បាប់ភូមិបាលឆ្នាំ ២០០១, មាត្រា៣៨ កថាខណ្ឌទី៦
១៨. ការស្រង់ទិន្នន័យដីធ្លីសហគមន៍សំរោងត្បូងឆ្នាំ ២០២៤

តតិយជនផ្សេងនេះ បង្ហាញថាប្រជាសហគមន៍បានបំពេញលក្ខខណ្ឌកាន់កាប់ដីដោយមានការដឹងឮជាសាធារណៈ និងដោយពិតប្រាកដ[១៩]។ ប្រជាសហគមន៍សំរោងត្បូងមករស់នៅទីតាំងបច្ចុប្បន្នដោយសន្តិវិធី និងមិនមានហិង្សាជាមួយនរណាឡើយ។ រយៈពេលនៃការរស់នៅរបស់សហគមន៍បានបង្ហាញច្បាស់ពីរយៈពេលកាន់កាប់ជាភោគីស្របច្បាប់ដូចដែលមានកំណត់នៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ដែលតាំងទីលំនៅតាំងពីឆ្នាំ១៩៩៦ ដែលនេះបង្ហាញពីលក្ខខណ្ឌរយៈពេលនៃការកាន់កាប់ជាភោគីស្របច្បាប់[២០]។ រហូតមកដល់បច្ចុប្បន្ននេះសហគមន៍នៅតែបន្តរស់នៅលើទីតាំងនេះ ដោយប្រកបរបរលក់ដូរនេសាទត្រី ចិញ្ចឹមត្រី បេះឈូកជាដើម ដោយពុំដែលអាក់ខានក្នុងការកាន់កាប់ដីធ្លីឡើយ ដែលនេះបង្ហាញថាសហគមន៍កាន់កាប់ដីធ្លីដោយគ្មានការអាក់ខាន[២១]។ បើផ្អែកលើស្ថានភាពជាក់ស្តែង រាជរដ្ឋាភិបាលបានកាត់ផ្ទៃបឹងតាមោកចំនួន៨០ដង[២២] ដើម្បីប្រគល់ដល់ក្រុមហ៊ុន បុគ្គលឯកជន និងស្ថាប័នផ្សេងៗទៀត ក្នុងការគ្រប់គ្រងដោយស្របច្បាប់ ខណៈប្រជាសហគមន៍សំរោងត្បូងដែលបានរស់នៅតាំងពីឆ្នាំ១៩៩៦ និងមិនស្ថិតនៅក្នុងបឹងតាមោកផងនោះ បែរជាមិនទទួលបានការកាន់កាប់ស្របច្បាប់ និងរងនូវការបណ្តេញចេញទៅវិញ។

ដោយផ្អែកលើទិដ្ឋភាពច្បាប់ និងសង្គម ប្រជាសហគមន៍សំរោងត្បូងគួរជាភោគីស្របច្បាប់ដែលអាចធ្វើលទ្ធកម្មនៃកម្មសិទ្ធិបាន និងមានសិទ្ធិដូចជាកម្មសិទ្ធិករ ក្នុងការប្រើប្រាស់ ចាត់ចែង និងអាស្រ័យផលលើដីធ្លីរបស់ខ្លួនដែលធ្លាប់កាន់កាប់ ហើយសហគមន៍អាចដាក់ពាក្យស្នើសុំចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ឬស្នើសុំអភិវឌ្ឍនៅនឹងកន្លែងបានផងដែរ។ ប្រសិនបើរដ្ឋត្រូវការទីតាំងដើម្បីអភិវឌ្ឍន៍ នោះរដ្ឋត្រូវតែពិចារណាយកច្បាប់ស្តីពីអស្សាមិករណ៍មកដោះស្រាយជូនប្រជាសហគមន៍ ពីព្រោះថាសហគមន៍មិនបានរស់នៅលើផ្ទៃដីបឹងតាមោកឡើយ។

---

១៩. ច្បាប់ភូមិបាលឆ្នាំ ២០០១, មាត្រា៣៨ កថាខណ្ឌទី២ និងទី៤

២០. ច្បាប់ភូមិបាលឆ្នាំ ២០០១, មាត្រា៣០

២១. ច្បាប់ភូមិបាលឆ្នាំ ២០០១, មាត្រា៣៨ កថាខណ្ឌទី៥

២២. អង្គការសមាគមជាងត្នោត, ផែនទីអន្តរកម្មផ្ទៃបឹងតាមោក https://teangtnaut.org/km/map-layer (ចូលមើលថ្ងៃទី ១៨ កក្កដា ២០២៤)។

# ១០. អនុសាសន៍

- ការកំណត់ទីតាំងណាមួយជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋជាគោលការណ៍ត្រូវមានការផ្សព្វផ្សាយនិងត្រូវទុកពេលឱ្យមានការប្ដឹងតវ៉ាពីអ្នកពាក់ព័ន្ធ។ ក៏ប៉ុន្តែយន្តការនេះកន្លងមកហាក់មិនមានការអនុវត្ត ឬអនុវត្តតែមិនទាន់បានពេញលេញ ដែលធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនបានបាត់បង់សិទ្ធិ និងផលប្រយោជន៍លើដីដែលពួកគេធ្លាប់បានកាន់កាប់។ ដូច្នេះអាជ្ញាធរពាក់ព័ន្ធចំពោះរឿងនេះ ត្រូវធានាថានៅពេលដែលកំណត់ទីតាំងណាមួយជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ត្រូវតែមានការចូលរួមពីប្រជាពលរដ្ឋ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ ជាពិសេសក្នុងដំណាក់កាលនៃដំណើរការ។
- ស្រដៀងគ្នានឹងអនុសាសន៍ខាងលើ តែពាក់ព័ន្ធនឹងការធ្វើអនុប្បយោគ។ កន្លងមកប្រជាពលរដ្ឋដែលស្ថិតនៅមូលដ្ឋានហាក់មិនដឹងអំពីដំណើរការ និងការធ្វើអនុប្បយោគផ្សេងៗដែលប៉ះពាល់ដល់ប្រយោជន៍របស់គាត់។ ដូច្នេះអាជ្ញាធរពាក់ព័ន្ធចំពោះរឿងនេះត្រូវធានាថានៅពេលដែលកំណត់ទីតាំងណាមួយដែលត្រូវធ្វើអនុប្បយោគ ត្រូវតែមានការចូលរួមពីប្រជាពលរដ្ឋ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ ជាពិសេសក្នុងដំណាក់កាលនៃនីតិវិធី។
- ការធ្វើវេទិកាសាធារណៈដែលបើកចំហសម្រាប់សាធារណជនគួរត្រូវបានធ្វើឡើងដើម្បីផ្សព្វផ្សាយ និងចោទជាសំណួរផ្សេងៗដើម្បីជំរុញការដោះស្រាយកាន់តែមានតម្លាភាព យុត្តិធម៌ និងអាចទទួលយកបានសម្រាប់អ្នករងផលប៉ះពាល់ផ្ទាល់ និងសាធារណជនទូទៅ។
- ទំនាស់ដីធ្លីមួយចំនួនអាចពាក់ព័ន្ធនឹងរឿងរដ្ឋប្បវេណី ដែលតម្រូវឱ្យមានការតវ៉ាតាមផ្លូវតុលាការក្នុងរឿងក្ដីរដ្ឋប្បវេណី ដែលត្រូវចំណាយពេលវេលាច្រើន និងត្រូវបង់ប្រាក់ប្រដាប់ក្ដី។ ដូច្នេះវាបានបង្កើតការលំបាកផ្នែកសេដ្ឋកិច្ច និងពេលវេលាសម្រាប់ប្រជាពលរដ្ឋក្រីក្រក្នុងការប្រើប្រាស់យន្តការតុលាការដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ខ្លួន។ ដូច្នេះរាជរដ្ឋាភិបាលគួរបង្កើតយន្តការពិសេសក្នុងករណីនេះ ជាបណ្ដឹងរដ្ឋបាល និងធានាថាពួកគេមិនត្រូវបង់ប្រាក់ក្នុងដំណើរការរឿងក្ដី។ បន្ថែមពីនេះ គួរបើកសិទ្ធិឱ្យតតិយជនអាចធ្វើជាដើមបណ្ដឹងជំនួសផងដែរ។
- អាជ្ញាធរថ្នាក់ជាតិ នៅពេលបានទទួលសំណូមពររកអន្តរាគមន៍ដំណោះស្រាយពីប្រជាពលរដ្ឋមូលដ្ឋាន គួរមានយន្តការចុះអង្កេត និងវាយតម្លៃជាក់ស្ដែងដោយផ្អែកលើគោលការណ៍ច្បាប់ និងសង្គម ដើម្បីឱ្យប្រជាពលរដ្ឋមានទំនុកចិត្ត។ ការបកស្រាយគួរត្រូវបានពន្យល់ដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់ឱ្យបានទូលំទូលាយ។
- ការដោះដូរលំនៅឋានប្រជាពលរដ្ឋណាមួយដោយសារការអភិវឌ្ឍ ត្រូវធានាថាប្រពលរដ្ឋដែលរស់នៅមូលដ្ឋានទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍនោះដែរ។ មានន័យថា អាទិភាព គឺអភិវឌ្ឍពួកគាត់នៅនឹងកន្លែង តែបើមិនអាចអភិវឌ្ឍនៅនឹងកន្លែងបានទេ នៅពេលមានការដោះដូរត្រូវធានាថាជីវភាព និងស្ថានភាពរស់នៅ

របស់ពួកគាត់មានភាពប្រសើរជាមុន ឬយ៉ាងហោចណាស់បានស្មើនឹងកន្លែងចាស់។

- ❑ ការចោទប្រកាន់ប្រជាពលរដ្ឋថាប្រើប្រាស់អំពើហឹង្សាលើអាជ្ញាធរ ឬប្រឆាំងនឹងអ្នករាជការសាធារណៈគួរត្រូវបានពីចារណា និងវាយតម្លៃឱ្យបានល្អិតល្អន់ចំពោះអង្គហេតុជាក់ស្តែង។ ជាពិសេសសហគមន៍ដីធ្លីដែលធ្វើសកម្មភាពការពារដីធ្លី ឬលំនៅឋានរបស់ពួកគេ ព្រោះក្នុងករណីខ្លះវាគឺជាការអនុវត្តសិទ្ធិដែលមិនគួរត្រូវបានចោទប្រកាន់ថាជាការប្រឆាំងចំពោះអ្នករាជការសាធារណៈនោះទេ។ម្យ៉ាងទៀត ប្រសិនបើលក្ខខណ្ឌនៃការកាន់កាប់របស់សហគមន៍ជាភោគៈស្របច្បាប់ នោះការមករារាំងប្រជាពលរដ្ឋរបស់អាជ្ញាធរក៏ជារឿងដែលមិនត្រឹមត្រូវនោះដែរ។

# ឧបសម្ព័ន្ធ

*ផែនទីសហគមន៍សំរោងត្បូងបច្ចុប្បន្នភាពឆ្នាំ ២០២៤*





(+855) 023 431 555

sttcambodia

https://teangtnaut.org/